# ការទទួលស្គាល់នូវបញ្ហាប្រឈម និងការវិវត្តនៃវិស័យកសិកម្ម

## នៅក្នុងបរិបទនៃការរីកចម្រើនសេដ្ឋកិច្ចកម្ពុជា

ក្នុងពេលថ្មីៗនេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានពិនិត្យឃើញថា មានការកើតឡើង នូវការបញ្ចេញទស្សនៈផ្សេងៗទាក់ទងទៅនឹងវិស័យកសិកម្ម ទីផ្សារកសិកម្ម និងការធ្វើចំណាកស្រុក ។ តាមការពិនិត្យឃើញនូវការបញ្ចេញទស្សនៈ និងតាមការស្រាវជ្រាវថ្មីៗរបស់ក្រសួង យើងបានដឹងថានឹងមានអ្វីកើតឡើងចំពោះមុខ ដែលជាបញ្ហាប្រឈមថ្មីៗរបស់កសិករក្នុងការដោះស្រាយជីវភាព និងការប្រកបមុខរបរកសិកម្ម ពីមុននិងរហូតមកដល់ក្នុងដំណាក់ពេលបច្ចុប្បន្ននេះ ក៏ដូចជាពេលអនាគត នៅកម្ពុជា ។ បញ្ហាប្រឈមដែលបានកើតឡើងនឹងកើតឡើងនោះប្រាកដណាស់វាបានវាយលុកទៅលើវិស័យកសិកម្មទាំងមូល ជាពិសេសការធ្វើកសិកម្មខ្នាតតូចគឺកសិករដែលទទួលបានប្រាក់ចំណូលពីរបរកសិកម្ម កើនឡើងតិចតួច ថេរ ឬតិចជាងមុនដោយសារទំហំដីកសិកម្មរបស់កសិករខ្នាតតូចគឺនៅដដែល ឬកាន់តែតិចទៅៗ ដោយសារការចែករំលែកទៅកូនចៅរបស់ពួកគាត់ជាមួយនឹងកំណើនសេដ្ឋកិច្ចកម្ពុជាបានកើនឡើងក្នុងល្បឿនថេរជាង៧%ក្នុងមួយឆ្នាំ ក្នុងរយៈពេលជិត២០ឆ្នាំកន្លងមកនេះ ។ ហេតុផលទាំងអស់នេះ គឺបានស្តែងចេញឲ្យឃើញកំលាំងពលកម្មក្នុងវិស័យកសិកម្ម បានធ្លាក់ចុះយ៉ាងគំហុកពី ៨០% នៅឆ្នាំ១៩៩៣ ៦០% នៅឆ្នាំ ២០០៥ និងបានធ្លាក់ចុះមកជិត ៤០% នៅឆ្នាំ២០១៧ ។ លទ្ធផលនេះបានបង្ហាញឲ្យឃើញថា មិនមែនជារឿងកើតឡើងចំឡែកតែចំពោះប្រទេសកម្ពុជាមួយនោះទេ បើតាមអ្វីដែលក្រសួង បានធ្វើការសិក្សាស្រាវជ្រាវនៅតាមបណ្តាប្រទេសអភិវឌ្ឍន៍ និងកំពុងអភិវឌ្ឍន៍មួយចំនួន បានពិនិត្យឃើញថាគឺជាដំណើរវិវត្តទៅដូចៗគ្នា ទាក់ទងទៅនឹងការធ្វើចំណាកស្រុករបស់ប្រជាជន/កសិករដែលបានដើរចេញពីស្រុកកំណើត និងការងារកសិកម្មរបស់ខ្លួន ទៅស្វែងរកការងារថ្មីប្រសើរជាងមុន ជាក់ស្តែងដូចជា៖

| | | |
|---|---|---|
| 1) ប្រទេសអង់គ្លេស៖ | នៅឆ្នាំ១៥០០ ចំនួនកសិករធ្វើការក្នុងវិស័យកសិកម្មមានចំនួន | ៥៦,៨% |
| | នៅឆ្នាំ១៧០០ | ៣៨,៩% |
| | នៅឆ្នាំ១៨០០ | ៣១,៧% |
| | នៅឆ្នាំ១៩០០ | ២,១% |
| | នៅឆ្នាំ២០០០ | ១,៥% |
| 2) ប្រទេសហូឡង់ | នៅឆ្នាំ១៥០០ ចំនួនកសិករធ្វើការក្នុងវិស័យកសិកម្មមានចំនួន | ៥៦,៨% |
| | នៅឆ្នាំ១៦០០ | ៤៨,៧% |
| | នៅឆ្នាំ១៨០០ | ៤០,៧% |

| | | | |
|---|---|---|---|
| | | នៅឆ្នាំ១៩៨១ | ៥,៣% |
| | | នៅឆ្នាំ២០០០ | ៣% |
| 3) | ប្រទេសអីតាលី | នៅឆ្នាំ១៤០០ ចំនួនកសិករធ្វើការក្នុងវិស័យកសិកម្មមានចំនួន | ៦០,៩% |
| | | នៅឆ្នាំ១៨០០ | ៥៧,៨% |
| | | នៅឆ្នាំ១៩៨០ | ១៥% |
| | | នៅឆ្នាំ២០០០ | ៥,២% |
| | | នៅឆ្នាំ២០១២ | ៣,៧% |
| 4) | ប្រទេសបារាំង | នៅឆ្នាំ១៤០០ ចំនួនកសិករធ្វើការក្នុងវិស័យកសិកម្មមានចំនួន | ៧១,៤% |
| | | នៅឆ្នាំ១៦០០ | ៦៧,៨% |
| | | នៅឆ្នាំ១៨០០ | ៥៩,២% |
| | | នៅឆ្នាំ១៩០០ | ៥,៦% |
| | | នៅឆ្នាំ២០១២ | ២,៩% |
| 5) | ប្រទេសថៃ | នៅឆ្នាំ១៩៧១ ចំនួនកសិករធ្វើការក្នុងវិស័យកសិកម្មមានចំនួន | ៧៦,៧% |
| | | នៅឆ្នាំ១៩៩០ | ៦៣,៩% |
| | | នៅឆ្នាំ២០០០ | ៤៨,៧% |
| | | នៅឆ្នាំ២០១០ | ៣៨,២% |
| | | នៅឆ្នាំ២០១៥ | ៣២,២៤% |
| 6) | ប្រទេសហ្វីលីពីន | នៅឆ្នាំ១៩៧៣ ចំនួនកសិករធ្វើការនៅវិស័យកសិកម្មមានចំនួន | ៥៦% |
| | | នៅឆ្នាំ១៩៨០ | ៥១,៨% |
| | | នៅឆ្នាំ២០០០ | ៣៧,០% |
| | | នៅឆ្នាំ២០១០ | ៣៣,២% |
| | | នៅឆ្នាំ២០១៥ | ២៩,១៥% |

7) ប្រទេសឥណ្ឌូនេស៊ី នៅឆ្នាំ១៩៧០ ចំនួនកសិករធ្វើការក្នុងវិស័យកសិកម្មមានចំនួន ៧៦,៧%

| | |
|---|---|
| នៅឆ្នាំ១៩៩០ | ៦៣,៩% |
| នៅឆ្នាំ២០០០ | ៥៨,៧% |
| នៅឆ្នាំ២០១៥ | ៣២,២៨% |

ក្រៅពីការធ្វើចំណាកស្រុកដើម្បីស្វែងរកការងារប្រសើរជាងមុន នៅក្នុងប្រទេសរបស់ខ្លួន ប្រជាជន/ប្រជាកសិករតាមបណ្តាប្រទេសនីមួយៗ បានធ្វើចំណាកស្រុកទៅកាន់បណ្តាប្រទេសនានាក្នុងពិភពលោកយើងនេះ ដែលគេបានគិតថាមានកម្រិតសេដ្ឋកិច្ចខ្ពស់ជាង ឬអាចទទួលបានប្រាក់ចំណូលខ្ពស់ជាងប្រទេសរបស់ខ្លួន កំពុងរស់នៅ ដូចជា៖ ប្រទេសឥណ្ឌាបានធ្វើចំណាកស្រុកទៅក្រៅប្រទេសមានជាង៣០,៨លាននាក់ ប្រទេសចិនមានជាង ១០លាននាក់ ប្រទេសអាមេរិកមានជាង៨លាននាក់ ប្រទេសជប៉ុនមានជាង៣,៦លាននាក់ ប្រទេសកូរ៉េមានជាង៧លាននាក់ ប្រទេសវៀតណាមមានជាង ៧ លាននាក់ ប្រទេសឥណ្ឌូនេស៊ីមានជាង៨លាននាក់ និងប្រទេសហ្វីលីពីនធ្វើចំណាកស្រុកក្រៅប្រទេសមានជាង១០,២លាននាក់ ។ល។

របកគំហើញមួយចំនួនតូចខាងលើនេះគឺពិតជាបានចូលរួមចំណែកក្នុងការឆ្លុះបញ្ចាំងឲ្យឃើញថាប្រមុខរាជរដ្ឋាភិបាលកម្ពុជាបាននិងកំពុងខិតខំដាក់ចេញនូវគោលយោបាយយុទ្ធសាស្ត្រនៃការអភិវឌ្ឍជាតិបានយ៉ាងត្រឹមត្រូវ ក្នុងការចូលរួមចែករំលែកការលំបាករបស់ប្រជាជន បើទោះបីវិស័យមួយចំនួននៅមានការយឺតយ៉ាវបន្តិចយ៉ាងណាក្តីទាក់ទងទៅនឹងការកៀរគររកទុនវិនិយោគកន្លងមក ។ យុទ្ធសាស្ត្រសំខាន់ៗរបស់ប្រមុខរាជរដ្ឋាភិបាលទាំងនោះរួមមាន៖

1) ការធ្វើអំពាវនាវដល់ប្រទេសកំពុងអភិវឌ្ឍន៍ និងអភិវឌ្ឍន៍ឲ្យទទួលយកពលករពីកម្ពុជា
2) ការដាក់ចេញនូវយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យឧស្សាហកម្ម ឆ្នាំ ២០១៥-២០២៥
3) ការធ្វើទំនើបកម្មវិស័យកសិកម្ម តាមអភិក្រមនិងក្នុងវិសាលភាពនិងល្បឿនកំណើនសេដ្ឋកិច្ចថ្មី
4) ការពង្រីកទីផ្សារកសិកម្ម តាមរយៈការទទួលយកការវិនិយោគសម្បទានដីសេដ្ឋកិច្ច (ដែលជាឱកាសមួយរបស់ប្រជាកសិករដែលរស់នៅតំបន់នោះមានការងារធ្វើ ជាមួយនឹងការទទួលបានបច្ចេកវិទ្យាថ្មីក្នុងការដាំដុះ ឆ្លើយតបតាមសេចក្តីត្រូវការទីផ្សារ ហើយកសិករដែលរស់នៅជុំវិញតំបន់នោះអាចចូលរួមផលិតនូវផលិតផលកសិកម្មក្នុងការនាំចេញជាមួយក្រុមហ៊ុន)ការងារនេះកំពុងលេចចេញជារូបរាងបណ្តើរៗតាមរយៈការវាយតម្លៃរបស់ក្រសួងនាពេលកន្លងមកនេះ ។ សូមបញ្ជាក់ថា តាមអ្វីដែលក្រសួងបានសាកសួរពីតំណាងក្រុមហ៊ុនវិនិយោគ បានបញ្ជាក់ឲ្យដឹងថា ការបោះទុនវិនិយោគលើការដាំដុះដំណាំឈើហូបផ្លែជិតមួយឆ្នាំកន្លងមកនេះ គឺធ្វើឡើងតាមការបញ្ជាទិញពីក្រុមហ៊ុនក្រៅប្រទេស

ដូចជា ប្រទេសជប៉ុន ចិន និងអូស្ត្រាលី ជាមួយនឹងការផ្តល់ជំនាញបច្ចេកទេសក្នុងការដាំដុះ និងវិចខ្ចប់ ព្រមទាំងផ្តល់ទុនដល់ក្រុមហ៊ុនមុនចាប់ផ្តើមនៃការដាំដុះ ចំនួន ១៥% ផងដែរ ។

5) ផែនការនៃការពង្រីកវិស័យហេដ្ឋារចនាសម្ព័ន្ធគាំទ្រ ដូចជា បណ្តាញគមនាគមន៍ កំពង់ផែទឹកជ្រៅ ១២ ម៉ែត្រ ព្រលានយន្តហោះនៅខេត្តសៀមរាប ថាមពលអគ្គិសនី (វារីអគ្គិសនី) ប្រព័ន្ធផ្គត់ផ្គង់ទឹក ។ល។ ក្នុងការទទួលបានការវិនិយោគពីក្នុង និងក្រៅប្រទេសបន្ថែមទៀត ជាពិសេស លើវិស័យកសិ-ឧស្សាហកម្ម ក្នុងការកែឆ្នៃផលិតផលកសិកម្មដែលកំពុងផលិតលើសពីតម្រូវផ្គត់ផ្គង់ក្នុងស្រុក និង

6) មានយុទ្ធសាស្ត្រសំខាន់ៗជាច្រើនទៀតក្នុងការជួយគាំទ្រដល់ការអភិវឌ្ឍវិស័យកសិកម្ម។

ការចូលរួមធ្វើរបកគំហើញរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អាចចាត់ទុកជាគតិមួយសម្រាប់យើងទាំងអស់គ្នា ជាពិសេសយុវជន ដើម្បីបានចូលរួមជាផ្លូងមួយរួមជាមួយរាជរដ្ឋាភិបាល ដែលមាន **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ជាប្រមុខដឹកនាំ ដ៏ឈ្លាសវៃ ក្នុងការកសាងប្រទេសដ៏កំសត់អោយទទួលបាននិរន្តរភាព ក្នុងការការពារសន្តិភាព និងការអភិវឌ្ឍជាតិ របស់យើង ។